# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២០៥ . អនក្រ . បក

# អនុក្រឹត្យ
## ស្ដីពី
## ការបំពេញបន្ថែមឯកសណ្ឋាន សញ្ញាសក្តិ និងមួក របស់អគ្គនាយកដ្ឋានកម្ពុជា ត្រួតពិនិត្យទំនិញនីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥/ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៤៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពី ឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាក សញ្ញាសំគាល់របស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ "កាំកុងត្រូល"
- បានឃើញអនុក្រឹត្យលេខ ១៤៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៧ ស្តីពីការបំពេញបន្ថែមឯកសណ្ឋាន របស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ "កាំកុងត្រូល"
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការដំឡើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) អោយទៅជាអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ចំណុះក្រសួងពាណិជ្ជកម្ម
- តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា ១ :**

បំពេញបន្ថែម អនុក្រឹត្យលេខ ១៤៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៧ ស្តីពីការបំពេញបន្ថែមឯកសណ្ឋាន របស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ "កាំកុងត្រូល" និងដាក់អោយប្រើប្រាស់ឯកសណ្ឋាន សញ្ញាសក្តិ និងមួក សំរាប់អគ្គនាយក-អគ្គនាយករង នៃអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ "កាំកុងត្រូល" ។

**មាត្រា ២ :**

ខ្លឹមសារដែលត្រូវបំពេញបន្ថែម ត្រូវបានកំណត់ដូចតទៅ ÷

**១- ឯកសណ្ឋាន :** មានបីប្រភេទ ដូចមានគំរូក្នុងឧបសម្ព័ន្ធ

**<u>ឯកសណ្ឋានសំរាប់ការងារ</u>**

- **ខោ** ជើងវែង ពណ៌ពងក្រសារ ផលិតអំពីសាច់ក្រណាត់តេហ្គាលឡែន ចង្កេះតថ្មេរ បង្កប់ ជីបភ្លឺខាងមុខពីរ មានហោប៉ៅបី " ហោប៉ៅខាងក្រោយមួយ ដេរបង្កប់មានគំរប រាងស្លឹកពោធិ និងហោប៉ៅពីរ ទៀតនៅចំហៀង ដេរបង្កប់តាមថ្មេរ" ។
- **អាវ** អាវដៃខ្លី មានពណ៌ និងសាច់ក្រណាត់ដូចខោ កបើក ថ្មេរឌុប ប៉ូលស្មា ជីប ចង្កេះ មានហោប៉ៅបួន" ហោប៉ៅពីរខាងលើដេរប៉ះ បត់ផ្នត់កណ្តាល មានគំរបរាងស្លឹកពោធិ ហោប៉ៅផ្លោកពីរខាងក្រោម ដេរប៉ះមានគំរបរាងស្លឹកពោធិ" ឡេវមុខ និងហោប៉ៅ រូបព្រះសង្ខា ពណ៌មាស ។

**<u>ឯកសណ្ឋានសំរាប់ពិធីការ</u>**

ប្រភេទអាវធំដៃវែង ផលិតអំពីសាច់ក្រណាត់តេហ្គាឡែន ពណ៌ពងក្រសារចាស់ កបើក ថ្មេរឌុប ប៉ូលស្មា ជីបភ្លឺខាងមុខពីរ មានឡេវធំពីក្រោមរហូតដល់លើពណ៌ទឹកមាស ហោប៉ៅបួន (ហោប៉ៅពីរខាងលើ បត់ផ្នត់កណ្តាល មានគំរបរាងស្លឹកពោធិ ដោយមានឡេវធំពណ៌មាស ហោប៉ៅពីរទៀតនៅក្រោម មានគំរបរាងចតុកោណកែង ដោយមាន ឡេវធំពណ៌មាស ។ ផ្នែកខាងក្រោយមាន ជីបភ្លឺចំនួនពីរ ឆ្វេងមួយ ស្តាំមួយ និងមានរែកចំកណ្តាលនៃអាវ ។

**<u>ឯកសណ្ឋានសំរាប់បំពេញប្រតិបត្តិការ នៅតាមព្រំដែន</u>**

ប្រភេទអាវដៃវែងពាក់ខាងក្រៅ ផលិតអំពីសាច់ក្រណាត់មួយរយភាគរយកូតុង មានពណ៌ខ្មៅប្រផេះ កបើក ថ្មេរឌុប មានឡេវរ៉ូតពីក្រោមរហូត ដល់លើ ផ្នែកខាងក្រោមមានក្រវ៉ាត់ចង្កេះសងខាង និង មានហោប៉ៅបួន (ហោប៉ៅពីរនៅខាងក្រោម ដេរបង្កប់តាមថ្មេរ ឆ្វេងមួយ ស្តាំមួយ និងហោប៉ៅពីរទៀត នៅខាងក្នុងអាវ ផ្នែកមុខ ឆ្វេងមួយ ស្តាំមួយ) ។ ផ្នែកមុខស្តាំដៃ ខាងលើ មានប៉ាក់អក្សរថា " **កាំកុងត្រូល** " ; ពណ៌ពងក្រសារ និងផ្នែកខាងក្រោយអាវ មានប៉ាក់អក្សរឡាតាំងរាងកោងបន្តិចចំកណ្តាល ថា" CAMCONTROL" ពណ៌ពងក្រសារ ។

២- សញ្ញាសក្តិ :

- **សញ្ញាសក្តិស្មា** មានពីរថ្នាក់ ដូចមានគំរូក្នុងឧបសម្ព័ន្ធ

• **ថ្នាក់អគ្គនាយក :**

មានផ្ទៃពណ៌ខៀវទឹកប៊ិច ក្បាច់ភ្ញីទេស ព័ទ្ធជុំវិញ ពណ៌មាស ប៉ាក់អក្សរ "កាំកុងត្រួល" ពណ៌មាស និងក្បាច់ទ្រខាងក្រោម រូបសញ្ញាសំគាល់របស់អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការ ក្លែងបន្លំ (កាំកុងត្រួល) រាងពងក្រពើ "ពណ៌មាស" ដែលនៅចំកណ្តាល និងមានរូបព្រះសង្ហា "ពណ៌មាស" នៅខាងចុងនៃសញ្ញាសក្តិ ។

• **ថ្នាក់អគ្គនាយករង :**

មានផ្ទៃពណ៌ខៀវទឹកប៊ិច ក្បាច់អង្គរ ព័ទ្ធជុំវិញ ពណ៌មាស ប៉ាក់អក្សរ "កាំកុងត្រួល" ពណ៌មាស និងក្បាច់ទ្រខាងក្រោមរូបសញ្ញាសំគាល់របស់ អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ-អាហរ័ណ និងបង្ក្រាបការ ក្លែងបន្លំ (កាំកុងត្រួល) "ពណ៌មាស" ព័ទ្ធអមដោយភ្ញីផ្កា និងរូបព្រះសង្ហា "ពណ៌មាស" នៅខាងចុងនៃសញ្ញាសក្តិ ។

៣- មួកៈ

- **មួកកាស្កែត** មានពីរថ្នាក់ ដូចមានគំរូក្នុងឧបសម្ព័ន្ធ

• **ថ្នាក់អគ្គនាយក :**

មួកកាស្កែតធ្វើពីក្រណាត់ពណ៌ដូចសំលៀកបំពាក់ ដែលផ្នែកខាងមុខ លើកណ្តាប៉ីណ្ឌ មានភ្ជាប់រូបព្រះសង្ហាពណ៌មាស ទំហំកំពស់ ៧.៨ ស.ម ទទឹង ៦.៨ ស.ម ប៉ែកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ហា មានក្បាច់ភ្ញីទេស ប៉ាក់ពណ៌មាស ដល់ជើងមួក និងខាងក្រោមក្បាច់ មានប៉ាក់វីណ្ឌពណ៌មាស ពីលើក្រណាត់ខ្សែន ពណ៌ខៀវទឹកប៊ិចព័ទ្ធជុំវិញ ព្រមទាំងនៅចុងខ្សែវណ្ឌ៍ ទាំងពីរខាង ភ្ជាប់ដោយឡេវរូបព្រះសង្ហា ពណ៌មាស។ ខាងក្រោមនៃប៉ាក់វីណ្ឌប៉ែកខាងមុខ មានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានប៉ាក់ក្បាច់ភ្ញីទេសប៉ាក់ពណ៌មាស ទម្រង់ស្លែងក្របីធំ ដល់ជើងមួក ។

• **ថ្នាក់អគ្គនាយករង :**

មួកកាស្កែតធ្វើពីក្រណាត់ពណ៌ដូចសំលៀកបំពាក់ ដែលផ្នែកខាងមុខ លើកណ្តាប៉ីណ្ឌ មានភ្ជាប់រូបព្រះសង្ហាពណ៌មាស ទំហំកំពស់ ៧.៨ ស.ម ទទឹង ៦.៨ ស.ម ប៉ែកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ហា មានប៉ាក់វីណ្ឌពណ៌មាស ពីលើក្រណាត់ខ្សែន ពណ៌ខៀវទឹកប៊ិចព័ទ្ធជុំវិញ ព្រមទាំងនៅចុងខ្សែវណ្ឌ៍ ទាំងពីរខាង ភ្ជាប់ដោយឡេវរូបព្រះសង្ហា ពណ៌មាស។ ខាងក្រោមនៃប៉ាក់វីណ្ឌប៉ែកខាងមុខ មានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានប៉ាក់ក្បាច់ភ្ញីទេសប៉ាក់ពណ៌មាស ទម្រង់ស្លែងក្របីធំ ដល់ជើងមួក ។

- មួក <u>**សំរាប់បំពេញប្រតិបត្តិការ នៅតាមព្រំដែន**</u> មានដូចមានគំរូក្នុងឧបសម្ព័ន្ធ

មួកកាតិប ធ្វើពីក្រណាត់កូតុងលាយតេហ្គាឡែន ពណ៌ខៀវប្រផេះ ដែលផ្នែកខាងមុខមានភ្ជាប់រូបព្រះសង្ហា " ពណ៌មាស " មានក្បាំងពណ៌ដូចតួមួក ដោយមានក្បាច់ភ្ញីទេស ឱនពណ៌មាស ទំរង់ស្នែងក្របីដល់ជើងមួក ។ ផ្នែកចំហៀង ខាងឆ្វេង មានប៉ាក់អក្សរ ថា " **កាំកុងត្រូល** " ពណ៌ពងក្រសារ និងផ្នែកចំហៀងខាងស្តាំ មានប៉ាក់អក្សរឡាតាំង ថា " CAMCONTROL " ពណ៌ពងក្រសារ ។

<u>**មាត្រា ៣**</u> **:**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៨

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខា
**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

<u>**កន្លែងទទួល**</u> **:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារកាលប្បវត្តិ